# ចុះឈ្មោះទុកជាមុន នៅអាយុ 16 ឆ្នាំ។ បោះឆ្នោតនៅអាយុ 18 ឆ្នាំ។

ការចុះឈ្មោះទុកជាមុនតាមអនឡាញគឺអាចស្វែងរកបានសម្រាប់បុគ្គលដែលមានអាយុ 16 និង 17 ឆ្នាំ ដែលមានសិទ្ធិគ្រប់គ្រាន់ តាមរយៈ **RegisterToVote.ca.gov**។* យុវជនរដ្ឋកាលីហ្វ័រញ៉ាដែលចុះឈ្មោះទុកជាមុនដើម្បីបោះឆ្នោត នឹងធ្វើឱ្យការចុះឈ្មោះរបស់ខ្លួនសកម្មនៅពេលដែលពួកគេគ្រប់អាយុ 18 ឆ្នាំ។

## 1. ចូលទៅកាន់

https://RegisterToVote.ca.gov

## 2. ចុះឈ្មោះទុកជាមុន

សូមចុចប៊ូតុង “Pre-Voter Registration” (ការចុះឈ្មោះអ្នកបោះឆ្នោតទុកជាមុន)។

## 3. គ្រប់អាយុ 18 ឆ្នាំ

ក្លាយជាអ្នកបានចុះឈ្មោះដោយស្វ័យប្រវត្តិនៅថ្ងៃកំណើតគម្រប់អាយុ 18 ឆ្នាំរបស់អ្នក។

## 4. បោះឆ្នោត

ធ្វើការបោះឆ្នោតនៅថ្ងៃបោះឆ្នោត!

*ការចុះឈ្មោះទុកជាមុនក៏អាចស្វែងរកបាននៅលើក្រដាសទម្រង់បែបបទការចុះឈ្មោះបោះឆ្នោតផងដែរ

## តើការចុះឈ្មោះទុកជាមុនគឺជាអ្វី?

ប្រសិនបើអ្នកមានអាយុ 16 ឬ 17 ឆ្នាំ ហើយបំពេញគ្រប់លក្ខខណ្ឌសិទ្ធិអ្នកបោះឆ្នោតផ្សេងទៀត អ្នកអាចចុះឈ្មោះបោះឆ្នោតទុកជាមុន តាមរយៈ RegisterToVote.ca.gov។

គ្រាន់តែបំពេញពាក្យសុំចុះឈ្មោះទុកជាមុនតាមអនឡាញ ហើយនៅថ្ងៃកំណើតគម្រប់អាយុ 18 ឆ្នាំរបស់អ្នក អ្នកនឹងត្រូវបានចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ។

## តើនរណាដែលអាចមានសិទ្ធិចុះឈ្មោះទុកជាមុន?

ដើម្បីចុះឈ្មោះបោះឆ្នោតទុកជាមុន អ្នកត្រូវតែ៖

- ជាពលរដ្ឋអាមេរិក និងជាអ្នករស់នៅរដ្ឋកាលីហ្វ័រញ៉ា
- អាយុ 16 ឬ 17 ឆ្នាំ
- បច្ចុប្បន្នមិនជាប់ពន្ធនាគាររដ្ឋឬសហព័ន្ធសម្រាប់ការផ្តន្ទាទោសពីបទឧក្រិដ្ឋ (សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ www.sos.ca.gov/elections/voting-resources/voting-california/who-can-vote-california/voting-rights-californians) ហើយ
- បច្ចុប្បន្នមិនត្រូវបានរកឃើញថាអសមត្ថភាពផ្លូវចិត្តក្នុងការបោះឆ្នោតដោយតុលាការនោះទេ (សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ www.sos.ca.gov/elections/voting-info/conservatorship)។

## ចុះប្រសិនបើអ្នកត្រូវការធ្វើបច្ចុប្បន្នភាពអាសយដ្ឋាន ឬគណបក្សនយោបាយដែលអ្នកពេញចិត្តមុនពេលអ្នកគ្រប់អាយុ 18 ឆ្នាំ?

ធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នក តាមរយៈ RegisterToVote.ca.gov។ ពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោតក៏អាចស្វែងរកបាននៅការិយាល័យបោះឆ្នោតខោនធីប្រចាំតំបន់របស់អ្នក នាយកដ្ឋានយានយន្ត និងការិយាល័យប្រៃសណីយ៍ផងដែរ។

## ដើម្បីស្វែងរកការិយាល័យបោះឆ្នោតខោនធីប្រចាំតំបន់របស់អ្នក សូមចូលទៅកាន់៖

www.sos.ca.gov/county-elections-offices

## ដើម្បីស្វែងយល់បន្ថែមស្តីពីការចុះឈ្មោះទុកជាមុន សូមចូលទៅកាន់៖

www.sos.ca.gov/elections/pre-register-16-vote-18

California | Secretary of State

CaliforniaSOS CASOSvote
CaliforniaSOS_ Californiasos

1500 11th Street, Sacramento, CA 95814
www.sos.ca.gov | (888) 345-4917